# ព័ត៌មានកម្ពុជាថ្ងៃនេះ

១៨ មីនា ២០២២

## ព័ត៌មានសំខាន់ៗ

1. នាយករដ្ឋមន្ត្រីជប៉ុន នឹងដឹកនាំគណៈប្រតិភូជាន់ខ្ពស់មកបំពេញទស្សនកិច្ចនៅកម្ពុជា ពីថ្ងៃទី២០-២១ ខែមីនា ដើម្បីពង្រឹងទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ។
   ប្រភព៖ ខ្មែរថាមស៍
2. រដ្ឋមន្ត្រីការបរទេសនៃព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីត នឹងមកបំពេញទស្សនកិច្ចផ្លូវការនៅកម្ពុជា ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី និងពិភាក្សាលើបញ្ហាផ្សេងៗក្នុងតំបន់ និងអន្តរជាតិ។
   ប្រភព៖ ខ្មែរថាមស៍
3. អគ្គនាយកដ្ឋានពន្ធដារ នឹងអនុវត្តអាករលើតម្លៃបន្ថែម (VAT) លើប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (E-Commerce) ខណៈដែលមានក្រុមហ៊ុនបរទេសមួយចំនួនបានចុះបញ្ជីរួច។
   ប្រភព៖ សារព័ត៌មានថ្មីៗ

## ព័ត៌មានសេដ្ឋកិច្ច

1. ក្រសួងពាណិជ្ជកម្ម បានពិភាក្សាចុងក្រោយលើផែនការយុទ្ធសាស្ត្រទាញយកអត្ថប្រយោជន៍ជាអតិបរមា ពីការអនុវត្ត FTA មុននឹងដាក់ជូនអន្តរក្រសួងពាក់ព័ន្ធចំនួន ១៥ ដើម្បីពិនិត្យ និងសម្រេច។
   ប្រភព៖ ទីភ្នាក់ងារសារព័ត៌មានកម្ពុជា
2. កម្ពុជា-ចិន បានចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់គ្នាលើកិច្ចសហប្រតិបត្តិការក្នុងវិស័យគ្រប់គ្រងមុខងារសារធារណៈ ដើម្បីពង្រឹងគុណភាពនៃវិស័យមុខងារសាធារណៈ។
   ប្រភព៖ AMS News
3. ការនាំចេញទំនិញរបស់កម្ពុជា ទៅកាន់កូរ៉េខាងត្បូង មានទំហំទឹកប្រាក់ប្រមាណ ៦៤,៥លានដុល្លារ ក្នុងរយៈពេល ០២ខែដំបូង ដែលជាការធ្លាក់ចុះ ០,៨% បើធៀបនឹងខែដដែលកាលពីឆ្នាំមុន។
   ប្រភព៖ ខ្មែរថាមស៍

## ព័ត៌មាននយោបាយ

1. គ.ជ.ប បានទទួលពាក្យបណ្តឹងសរុបចំនួន ១៦៦បណ្តឹង ដែលជាបណ្តឹងរបស់ប្រជាពលរដ្ឋ ពាក់ព័ន្ធជាមួយបេក្ខជនឈរឈ្មោះរបស់គណបក្សភ្លើងទៀនដែលមិនចេះអក្សរ។
   ប្រភព៖ ភ្នំពេញប៉ុស្តិ៍
2. សាលាដំបូងរាជធានីភ្នំពេញ បានប្រកាសសាលក្រមកាត់ទោសលោក សម រង្ស៊ី និងមនុស្សចំនួន ០៦នាក់ផ្សេងទៀតឱ្យជាប់ពន្ធនាគារម្នាក់ ១០ឆ្នាំ ក្រោមបទចោទចំនួន ០៣។
   ប្រភព៖ សារព័ត៌មានថ្មីៗ
3. រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន បានបញ្ចប់កិច្ចប្រជុំចង្អៀតលើកទី២៨ ដោយយល់ព្រមលើផែនការការងារសម្រាប់ឆ្នាំ២០២២ ក្នុងការកំណត់អាទិភាពឆ្ពោះទៅរកការស្តារសេដ្ឋកិច្ចក្នុងតំបន់។
   ប្រភព៖ ខ្មែរថាមស៍

## ព័ត៌មានសង្គម

1. សម្តេចតេជោនាយករដ្ឋមន្ត្រី បានមានប្រសាសន៍ថា ទោះជាស្ថិតក្នុងស្ថានការណ៍ណាក៏ដោយ កម្ពុជាមានស្បៀងសម្រាប់បម្រុងទុករហូតទៅដល់ ៥លានតោន។
   ប្រភព៖ AMS News
2. ក្រសួងទេសចរណ៍ បានណែនាំដល់មន្ត្រីជំនាញ ស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្រ ស្តីពីការបើកទទួលទេសចរណ៍វ៉ាក់សាំង និងគោលនយោបាយជំរុញទេសចរណ៍ផ្ទៃក្នុង។
   ប្រភព៖ ទីភ្នាក់ងារសារព័ត៌មានកម្ពុជា
3. សម្តេចតេជោនាយករដ្ឋមន្ត្រី បានលើកទឹកចិត្តឱ្យអង្គការ Asia Foundation បន្តរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា ជាពិសេសក្នុងអំឡុងនៃវិបត្តិជំងឺកូវីដ១៩។
   ប្រភព៖ ទីភ្នាក់ងារសារព័ត៌មានកម្ពុជា

Cambodia Development Center
info@cd-center.org
(+855) 10 950 456
www.cd-center.org

©រក្សាសិទ្ធិប្រើប្រាស់ដោយមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា | ២០២២